ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

# ក្រមសីលធម៌

# សំរាប់សវនករផ្ទៃក្នុង

# សេចក្តីផ្តើម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញផ្សាយក្រមសីលធម៌នេះ ដោយអនុលោមតាមមាត្រា ៨ នៃអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។ ក្រមសីលធម៌នេះផ្តល់នូវការណែនាំអំពីគោលការណ៍ និងវិធាននានាដល់សវនករផ្ទៃក្នុង ដែលបំពេញការងារក្នុងស្ថាប័នរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។ គោលបំណងនៃក្រមសីលធម៌គឺលើកតំកើង វប្បធម៌ សីលធម៌ ក្នុងវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ។

សវនកម្មផ្ទៃក្នុងគឺជាការធានាដោយឯករាជ្យ និងមិនលំអៀង និងជាសកម្មភាពពិគ្រោះយោបល់ ដែលបង្កើតឡើង ដើម្បីបន្ថែមតំលៃ និងធ្វើអោយប្រតិបត្តិការរបស់អង្គភាពកាន់តែប្រសើរ ។ សវនកម្មផ្ទៃក្នុងជួយអង្គភាពអោយសំរេចនូវ គោលបំណងរបស់ខ្លួនដោយនាំមកនូវអភិក្រមដែលមានលក្ខណៈជាប្រព័ន្ធ និងជំនាញ ដើម្បីវាយតំលៃ និងធ្វើអោយ ប្រសើរនូវការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការអភិបាលកិច្ច ។

វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ត្រូវការចាំបាច់នូវក្រមសីលធម៌ ដែលបង្កើតនូវការជឿជាក់លើភាពមិនលំអៀងក្នុងការ គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការអភិបាលកិច្ច ។ ក្រមសីលធម៌បានរួមបញ្ចូលនូវសមាសភាគសំខាន់ ពីរបន្ថែមទៅលើនិយមន័យសវនកម្មផ្ទៃក្នុងគឺ :

១. "គោលការណ៍" ពាក់ព័ន្ធនឹងវិជ្ជាជីវៈ និងការអនុវត្តសវនកម្មផ្ទៃក្នុង

២. "វិធាន" ដែលពិពណ៌នាអំពីតំរូវការនៃបទដ្ឋានឥរិយាបថរបស់សវនករផ្ទៃក្នុង ។ វិធានទាំងនេះជាជំនួយក្នុងការ អនុវត្ត "គោលការណ៍ " និងដើម្បីណែនាំសវនករផ្ទៃក្នុងប្រតិបត្តិបានត្រឹមត្រូវនូវក្រមសីលធម៌ ។

## គោលការណ៍

សវនករផ្ទៃក្នុងត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម:

### ក) ភាពសុចរិត

ភាពសុចរិតរបស់សវនករផ្ទៃក្នុងបង្កើតនូវការទុកចិត្ត និងជាមូលដ្ឋានបំរើអោយការជឿជាក់លើការវិនិច្ឆ័យរបស់ សវនករ ។

### ខ) ភាពមិនលំអៀង

សវនករផ្ទៃក្នុងរក្សាភាពមិនលំអៀងលើវិជ្ជាជីវៈកំរិតខ្ពស់ ក្នុងការប្រមូល ការវាយតំលៃ និងរាយការណ៍ព័ត៌មាន អំពីសកម្មភាព ឬដំណើរការដែលបានពិនិត្យ ។ សវនករផ្ទៃក្នុងធ្វើការវាយតំលៃយ៉ាងត្រឹមត្រូវនៅគ្រប់កាលៈទេសៈទាំងអស់ ដោយពុំគិតផលប្រយោជន៍ផ្ទាល់ខ្លួន និងឥទ្ធិពលអ្នកដទៃនៅក្នុងការវិនិច្ឆ័យនោះទេ ។

**ឥ) ការសំងាត់**

សវនករផ្ទៃក្នុងគោរពតំលៃ និងកម្មសិទ្ធិនៃព័ត៌មានដែលបានទទួល និងមិនផ្សព្វផ្សាយព័ត៌មានដោយគ្មានការអនុញ្ញាត លើកលែងតែមានកាតព្វកិច្ចក្នុងផ្លូវច្បាប់ ឬក្នុងវិជ្ជាជីវៈក្នុងការផ្សព្វផ្សាយព័ត៌មាននោះ ។

**ឃ) សមត្ថភាព**

សវនករផ្ទៃក្នុងប្រើចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលចាំបាច់ក្នុងការអនុវត្តសកម្មភាពសវនកម្មផ្ទៃក្នុង ។

**វិធាន**

**ក) ភាពសុចរិត**

សវនករផ្ទៃក្នុង:

- ត្រូវអនុវត្តការងាររបស់ខ្លួនដោយស្មោះត្រង់ ប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់
- ត្រូវប្រតិបត្តិតាមច្បាប់ និងផ្សព្វផ្សាយព័ត៌មានដែលតំរូវដោយច្បាប់ និងវិជ្ជាជីវៈ
- មិនត្រូវចូលរួមក្នុងសកម្មភាពមិនស្របច្បាប់ ឬក្នុងសកម្មភាពដែលនាំអោយប៉ះពាល់ដល់វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ឬកិត្តិយសរបស់រាជរដ្ឋាភិបាល
- ត្រូវគោរព និងរួមចំណែកក្នុងគោលដៅស្របច្បាប់របស់រាជរដ្ឋាភិបាល ។

**ខ) ភាពមិនលំអៀង**

សវនករផ្ទៃក្នុង:

- មិនត្រូវចូលរួមក្នុងសកម្មភាព ឬទំនាក់ទំនងដែលអាចធ្វើអោយប៉ះពាល់ ឬដែលគិតថាអាចប៉ះពាល់ដល់ការវាយតំលៃប្រកបដោយភាពមិនលំអៀងរបស់ខ្លួន និងអាចប៉ះពាល់ដល់ផលប្រយោជន៍របស់រាជរដ្ឋាភិបាល
- មិនត្រូវទទួលយកអ្វីដែលអាចប៉ះពាល់ ឬដែលគិតថាអាចប៉ះពាល់ដល់ការវិនិច្ឆ័យតាមលក្ខណៈវិជ្ជាជីវៈរបស់ខ្លួន
- ត្រូវបង្ហាញរាល់ហេតុការណ៍ជាសារវន្ត ដែលសវនករដឹងថា ប្រសិនបើមិនបង្ហាញនោះទេ របាយការណ៍ស្តីពីសកម្មភាពដែលត្រូវបានពិនិត្យ និងខុសពីការពិត ។

**គ) ការសំងាត់**

សវនករផ្ទៃក្នុង:

- ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ និងការពារព័ត៌មាន ដែលបានទទួលក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន
- មិនត្រូវប្រើប្រាស់ព័ត៌មានសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផ្ទុយនឹងច្បាប់ ឬធ្វើអោយប៉ះពាល់ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**យ) សមត្ថភាព**

សវនករផ្ទៃក្នុង:

- ត្រូវធ្វើសវនកម្មលើសកម្មភាពណាដែលខ្លួនមានចំណេះដឹង ជំនាញ និងបទពិសោធន៍ច្បាស់លាស់
- ត្រូវអនុវត្តការងារសវនកម្មផ្ទៃក្នុងដោយអនុលោមតាមស្តង់ដារជាវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ត្រូវបង្កើនជំនាញ ប្រសិទ្ធភាព និងគុណភាពនៃការងាររបស់ខ្លួន ។